# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់នៅទួលក្រសាំង
# ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨
*ជួសជុលព្រះសហគមន៍តាមរបៀបសន្តហ្វ្រង់ស្វ័រ*

| |
|---|
| អត្ថបទទី១៖ យប ១៩,២១-២៧<br>ដំណឹងល្អ៖ លក ១០,១-១២ |

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងគោរពសន្តហ្វ្រង់ស្វ័រនៃទីក្រុងអាស៊ីស៊ី នៅក្នុងជីវិតរបស់គាត់ធ្លាប់បានយល់សុបិនថា "**ឃើញវិសាលវិហាររបស់សម្តេចប៉ាបកំពុងដួល ហើយគាត់បានទ្រវិសាលវិហារនេះកុំឲ្យដួល ក្រោយមកគាត់លឺព្រះសូរសៀងថា ហ្វ្រង់ស្វ័រអើយសូមជួសជុលព្រះវិហារខ្ញុំ**"។ ក្រោយមកគាត់បានដើរនៅកន្លែងមួយ ហើយគាត់ឃើញមានព្រះវិហារមួយកំពុងដួលហើយគាត់បានជួសជុលដោយដៃរបស់គាត់។ ប៉ុន្តែបន្តិចម្តងៗគាត់យល់ថា ព្រះសូរសៀងរបស់ព្រះជាម្ចាស់ដែលថា "**សូមជួសជុលព្រះវិហាររបស់ខ្ញុំ**" ប្រហែលព្រះជាម្ចាស់មិនចង់និយាយអំពីអាគារ ប៉ុន្តែចង់និយាយអំពីចិត្តគំនិតរបស់គ្រីស្តបរិស័ទ និងចិត្តគំនិតរបស់មនុស្សលោក។

ថ្ងៃនេះយើងចូលនៅក្នុងព្រះវិហារ ដែលលោកឪពុកបានខិតខំជួសជុល យើងនឹកឃើញដែរយើងមិនចូលនៅក្នុងព្រះវិហារមួយយ៉ាងស្អាត ប៉ុន្តែឲ្យយើងជួសជុលចិត្តមនុស្សលោក។ មានន័យថាយើងអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូ "**សូមប្រាប់អ្នកភូមិថាព្រះរាជ្យរបស់ព្រះជាម្ចាស់នៅជិតអ្នករាល់គ្នាហើយ**"។ យើងទាំងអស់គ្នាដែលជាព្រះសហគមន៍ យើងត្រូវតែប្រកាសដំណឹងល្អរបស់ព្រះយេស៊ូដល់យើងផ្ទាល់ខ្លួនសិន ដល់ព្រះសហគមន៍របស់យើង ដែលព្រះយេស៊ូបានណែនាំឲ្យយើងបង្កើតពិភពថ្មី ដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ដែលចេះទទួលអ្នកតូចតាចដែលចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ សន្តហ្វ្រង់ស្វ័រ បានថើបមនុស្សដែលកើតជំងឺឃ្លង់នៅតាមផ្លូវ ដើម្បីបង្ហាថាគាត់ស្រឡាញ់មនុស្សទាំងអស់ ជាពិសេសមនុស្សដែលសង្គមស្អប់ខ្ពើម និងបោះបង់ចោល។ សម្រាប់យើង បើយើងចង់ជួសជុលដួងចិត្តរបស់យើង ជួសជុលពិភពលោករបស់យើង ឲ្យយើងយកចិត្តទុកដាក់ជាមួយមនុស្សដែលនៅជុំវិញយើង ជាមួយអ្នកតូចតាចជាមួយអ្នកដែលគ្មានសេចក្តីសង្ឃឹម ជាមួយអ្នកដែលគ្មានទីពឹង។ ថ្ងៃនេះយើងបានទៅជាមួយលោកឪពុកដុស លោកឪពុកលី និងអង្គការការីតាស យើងបានទៅមណ្ឌលសកម្មភាពទន្លេមេគង្គ ដើម្បីសួរសុខទុក្ខបងប្អូនដែលបានរងគ្រោះដោយសារទឹកជំនន់ ដើម្បីបងបង្ហាញថាព្រះសហ

គមន៍ និងព្រះយេស៊ូបានយកចិត្តទុកដាក់ជាមួយបងប្អូនទាំងអស់ ព្រោះយើងទាំងអស់គ្នាយើងជាគ្រួសារតែមួយ។

សន្តប្រាំង់ស្វ័រ បានកោតសរសើរអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើត គាត់បាននិពន្ធបទចម្រៀងមួយ បងព្រះអាទិត្យ បងព្រះចន្ទ បងផ្កាយ និងអ្វីៗទាំងអស់ដែលយើងចេះស្រឡាញ់គ្នាអស់ពីដួងចិត្ត។ ដើម្បីប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់ ឲ្យយើងយកចិត្តទុកដាក់នឹងអ្វីៗដែលព្រះជាម្ចាស់ប្រទានឲ្យ ដើម្បីឲ្យបក្សាបក្សីរកឃើញសេចក្តីសុខនៅក្នុងផែនដីរបស់យើង។ យើងបានទទួលផែនដីទុកជាមរតក ឲ្យយើងធ្វើយ៉ាងណាដើម្បីឲ្យផែនដីនេះស្អាតដើម្បីទុកឲ្យមនុស្សទាំងអស់ពោរពេញដោយសេចក្តីសុខ ដូចជាសត្វទាំងឡាយដែរ។

យើងនឹកឃើញដល់ របៀបដែលសន្តប្រាំង់ស្វ័រច្រៀងលើកតម្កើងសេចក្តីសុខសាន្ត ដែលជាអាទិភាពនៃជីវិតរបស់យើងគាត់ ដូចព្រះយេស៊ូមានព្រះបន្ទូលថ្ងៃនេះថា "**នៅពេលអ្នកចូលនៅក្នុងផ្ទះណាត្រូវនិយាយថា សូមព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តដល់មនុស្សដែលនៅក្នុងផ្ទះនេះ**"។ សន្តប្រាំង់ស្វ័រ បានទូលអង្វរនៅកន្លែងណាដែលមានសង្គ្រាមឲ្យយើងបង្កើតសេចក្តីសុខសាន្ត នៅកន្លែងណាដែលមានការស្អប់គ្នាឲ្យយើងចេះស្រលាញ់គ្នា នៅកន្លែងណាដែលមានការមើលងាយគ្នាឲ្យយើងចេះលើកលែងទោសឲ្យគ្នា ដោយសារយើងជាបងប្អូនបង្កើត។

ហេតុនេះហើយ យើងសរុបបីចំណុចដែលព្រះយេស៊ូណែនាំឲ្យថ្ងៃនេះ តាមរយៈសន្តប្រាំង់ស្វ័រ គឺទីមួយ ឲ្យយើងចាប់អារម្មណ៍ជាមួយបងប្អូនឯទៀតៗ ឲ្យយើងស្រឡាញ់អ្នកតូចតាច ឲ្យយើងចេះបម្រើគេ។ ទីពីរ ឲ្យយើងស្រឡាញ់បរិស្ថាន ផែនដី ធម្មជាតិ សត្វទាំងឡាយ ដើម្បីបង្កើតសុខដមរមនានៅក្នុងសង្គមបច្ចុប្បន្ននេះ។ ទីបី ឲ្យយើងធ្វើជាទូតនៃសេចក្តីសុខសាន្ត ប្រហែលសម្រាប់ពិភពលោកធំពេកប៉ុន្តែយ៉ាងតិចសម្រាប់យើង សម្រាប់ព្រះសហគមន៍របស់យើង ឲ្យយើងទៅជាបងប្អូនបង្កើតនៅក្នុងសេចក្តីស្រឡាញ់ ដើម្បីបង្ហាញថា ពិតមែនសេចក្តីសុខសាន្តជាអាទិភាពសម្រាប់យើងដែលជាសាវ័ករបស់ព្រះគ្រីស្ត។

របៀបដែលព្រះយេស៊ូបានណែនាំក្រុមគ្រីស្តទូតទាំង៧២នាក់ ព្រះយេស៊ូមានព្រះបន្ទូលថា "**នៅពេលអ្នករាល់គ្នាចូលនៅក្នុងភូមិណា បើមានគេទទួលស្វាគមន៍អ្នករាល់គ្នាចូរបរិភោគម្ហូបអាហារដែលគេរៀបជូនចុះ**"។ ឲ្យយើងបរិភោគជាមួយគេ អង្គុយលេងជាមួយគេ ឲ្យយើងសួរសុខទុក្ខគ្នាទៅវិញទៅមក មុនយើងនិយាយអំពីព្រះបន្ទូល មុនយើងនិយាយអំពីទស្សនៈនៃជីវិត ឲ្យយើងសួរសុខទុក្ខគ្នាទៅវិញទៅមក។ មុននិយាយអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយហើយ មុនប្រកាសដំណឹងល្អ ត្រូវប្រោសអ្នកជំងឺនៅក្នុងភូមិនោះឲ្យបានជាសះស្បើយ ឲ្យយើង

មានសកម្មភាពជាក់ស្តែង សេចក្តីត្រូវការរបស់គេជាគីអ្វី? ព្រះយេស៊ូយល់អំពីចិត្តមនុស្ស អង្គុយហូបអាហារជាមួយគេ ដើម្បីស្គាល់គ្នាទៅវិញទៅមក ស្តាប់សេចក្តីត្រូវការរបស់គេយ៉ាងពិតប្រាកដ ចិញ្ចឹមគេទៅឲ្យគេពោរពេញដោយអំណរសប្បាយ។

ព្រះយេស៊ូមានព្រះបន្ទូលថា "**សុំប្រាប់គេព្រះរាជ្យរបស់ព្រះជាម្ចាស់ នៅជិតអ្នករាល់គ្នាហើយ**" អង្គុយលេងជាមួយគេ ព្យាបាលតាមសេចក្តីត្រូវការ។ ព្រះជាម្ចាស់ជាអ្នកប្រទានជំនឿឲ្យគេ យើងផ្តល់សក្ខីភាព យើងស្រឡាញ់គេ យើងបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធបាន ក្រោយមកយើងទុកឲ្យព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការជំនួសយើង។ នៅឆ្នាំ២០០៣ ខ្ញុំបានទៅសួរសុខទុក្ខគ្រួសារផ្ទុកមេរោគអេដស៍នៅខេត្តកំពតជារៀងរាល់អាទិត្យ ១៤ឆ្នាំក្រោយមកគាត់បានសុំធញ្ញាជំហានទីមួយដើម្បីធ្វើជាគ្រីស្តបរិស័ទ។ ឲ្យយើងអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូ មានន័យថាដោយចិញ្ចឹមគេ អង្គុយជាមួយគេ យល់អំពីសេចក្តីត្រូវការរបស់គេ ឲ្យអាគារដែលយើងមាននៅទីនេះក្លាយជាអាគារពិសេសរបស់ព្រះសហគមន៍ទួលក្រសាំងយើង ដើម្បីឲ្យយើងទទួលស្វាគមន៍មនុស្សដែលគ្មានទីពឹង។ ឲ្យអ្នកដែលគ្មានទីពឹង អ្នកតូចតាច ជនពិការ អ្នកក្រីក្រ កុមារកំព្រា ឲ្យយើងធ្វើឲ្យកន្លែងរបស់យើងទៅជាកន្លែងមួយពិសេស ដើម្បីអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូថ្ងៃនេះ។ ឲ្យកន្លែងនេះទៅជាកន្លែងពិសេស ដើម្បីធ្វើជាពន្លឺនៃមេត្តាករុណាសម្រាប់បងប្អូនឯទៀតៗ ឲ្យយើងឃើញរូបសញ្ញានៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលឃើញជាក់ស្តែងនៅទីនេះ តាមរបៀបសន្តប្រហ្វង់ស្វ័រ។

យើងអរព្រះគុណព្រះជាម្ចាស់ ទូលអង្វរព្រះជាម្ចាស់តាមរយៈសន្តប្រហ្វង់ស្វ័រឲ្យយើងពោរពេញដោយសេចក្តីស្រឡាញ់ចំពោះបងប្អូនឯទៀតៗ ចំពោះផែនដីទាំងមូល និងជាពិសេសឲ្យយើងបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់ពោរពេញដោយសេចក្តីសុខសាន្ត។ អាម៉ែន៕